ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦

**ជូនចំពោះ រដ្ឋមន្ត្រីការបរទេសនៃបណ្តារដ្ឋជាសមាជិកសហភាពអឺរ៉ុប និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍**

ឯកឧត្តម/លោកជំទាវ,

យើងខ្ញុំ ជាតំណាងជាប់ឆ្នោតមកពីសហភាពអឺរ៉ុប និងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារគោលការណ៍សិទ្ធិមនុស្ស និងអភិបាលកិច្ចបែបប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាលើលិខិតនេះ សូមទទូចសុំឯកឧត្តមរដ្ឋមន្ត្រី ចាត់វិធានការជាបន្ទាន់ ដើម្បីជានាឲ្យមានការដោះលែងអ្នកទោសមនសិការទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារដោយខុសច្បាប់។

យើងខ្ញុំ មានការព្រួយបារម្ភចំពោះការរួមតូចនៃលំហសម្រាប់សង្គមស៊ីវិល នៅក្នុងតំបន់ និងការប្រែប្រួលយ៉ាងខ្លាំងឆ្ងាយពីការអះអាងអំពីការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីសិទ្ធិមនុស្ស នីតិវិធីត្រឹមត្រូវ និងគោលការណ៍លទ្ធិប្រជាធិបតេយ្យ។ ក្នុងបរិបទនៃការប្រែប្រួលនេះ អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន អ្នកកាសែត អ្នកនយោបាយ និងសមាជិកនៃក្រុមប្រជាពលរដ្ឋដែលឯករាជ្យ សហជីព និងអង្គការសាសនាជាច្រើនឡើងត្រូវបានចាប់ខ្លួន កាត់ទោស និងឃុំខ្លួន ដោយសារសកម្មភាពនយោបាយដោយសន្តិវិធី និងការអនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេ។

- នៅក្នុងប្រទេសម៉ាឡេស៊ី អតីតមេដឹកនាំគណបក្សប្រឆាំង Anwar Ibrahim កំពុងជាប់ឃុំ ក្រោមបទចោទដែលមានលក្ខណៈនយោបាយ ដោយហេតុនៃការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិរបស់គាត់។

- នៅក្នុងប្រទេសវៀតណាម មេធាវី Nguyen Van Dai ត្រូវបានឃុំខ្លួនជាថ្មីឡើងវិញ ដោយហេតុនៃការងារការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋជាជនរួមជាតិរបស់គាត់ ខណៈដែលអ្នកសរសេរប្លុក Nguyen Huu Vinh និង Nguyen Thi Minh Thuy កំពុងអនុវត្តទោសពន្ធនាគារដោយសារបានសរសេរិះគន់រដ្ឋាភិបាលនៅលើប្រព័ន្ធអ៊ីនធឺណែត។

- នៅក្នុងប្រទេសកម្ពុជា បុគ្គលិកសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (អាដហុក) ដែលជាអង្គការមិនមែនរដ្ឋាភិបាលដ៏សំខាន់មួយ ត្រូវបានឃុំខ្លួន ដោយសារការងារការពារសិទ្ធិមនុស្សស្របច្បាប់ និងការផ្តល់ជំនួយផ្នែកច្បាប់របស់ពួកគាត់ ខណៈដែលសកម្មជនសិទ្ធិដីធ្លី ទេព វន្នី ត្រូវបានឃុំខ្លួន ពាក់ព័ន្ធនឹងការតវ៉ាកាលពីឆ្នាំ២០១៣ ដើម្បីទាមទារឲ្យដោះលែងសកម្មជនដីធ្លីរបស់ខ្លួនដទៃទៀត។

- នៅក្នុងប្រទេសថៃ អ្នកកាសែត និងសកម្មជន Somyot Prueksakasemsuk កំពុងជាប់ឃុំដោយសារការផ្សព្វផ្សាយនូវព័ត៌មានដែលត្រូវបានចាត់ទុកថា"ជាការវាយប្រហារ"ដោយរដ្ឋាភិបាលនៃប្រទេសរបស់គាត់។

- នៅក្នុងប្រទេសមីយ៉ាន់ម៉ា កម្មកររោងចក្រ និងសមាជិកសហជីពនិស្សិតចំនួន ១៥នាក់ ត្រូវបានឃុំខ្លួន និងប្រឈមនឹងការចោទប្រកាន់ចំពោះការតវ៉ាដោយសន្តិវិធីរបស់ពួកគេ ក្នុងការទាមទារលក្ខខណ្ឌការងារប្រសើរជាងមុន។

- នៅក្នុងប្រទេសឡាវ Thongpaseuth Keuakoun និង Sengaloun Phengphanh សមាជិកចលនានិស្សិតឡាវ ដើម្បីលទ្ធិប្រជាធិបតេយ្យ ត្រូវបានឃុំខ្លួនតាំងពីឆ្នាំ១៩៩៩ ដោយសារការរៀបចំគម្រោងធ្វើបាតុកម្មទាមទារលទ្ធិប្រជាធិបតេយ្យ យុត្តិធម៌សង្គម និងការគោរពសិទ្ធិមនុស្ស។

ទាំងនេះគ្រាន់តែជាករណីមួយចំនួនតូចពីបញ្ជីដ៏វែងនៃប្រជាពលរដ្ឋអាស៊ីអាគ្នេយ៍ ដែលត្រូវបានឃុំខ្លួនជាអ្នកទោសមនសិការ ដែលសេរីភាពរបស់ពួកគេគឺមានសារៈសំខាន់ណាស់ចំពោះអនាគតអាស៊ានក្នុងនាមជាដៃគូដ៏ប្រសើររបស់សហភាពអឺរ៉ុប និងជាសហគមន៍តំបន់ ដែលគោរពបទដ្ឋានអន្តរជាតិ និងនីតិរដ្ឋ។

ខណៈដែលតំបន់ទាំងពីររបស់យើងកំពុងបន្តរឹតចំណងនយោបាយ និងសេដ្ឋកិច្ច កាន់តែមានភាពចាំបាច់ក្នុងការធានាថា សិទ្ធិមនុស្ស និងការប្តេជ្ញាចិត្តពិតប្រាកដចំពោះយុត្តិធម៌សង្គម បង្កើតនូវអាទិភាពរួមគ្នា ដែលពង្រីកលើសពីវោហាសាស្ត្រ ហើយបញ្ចូលទៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាល។

កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន-អឺរ៉ុប លើកទី២១ នាពេលខាងមុខ ដែលនឹងប្រារព្ធនៅទីក្រុងបាងកកប្រទេសថៃ នៅថ្ងៃទី១៤ ខែតុលា តំណាងឲ្យឱកាសដ៏ល្អបំផុត ដើម្បីជម្រុញគោលបំណងនេះ។ វាផ្តល់នូវឱកាសសម្រាប់មេដឹកនាំអាស៊ាន ដើម្បីបង្ហាញការប្តេជ្ញាចិត្តរបស់ពួកគេ ក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ និងសេរីភាពប្រជាពលរដ្ឋរបស់ពួកគេ ហើយផ្តល់ដល់ដៃគូអឺរ៉ុបរបស់ពួកគេ នូវទីកន្លែងដើម្បីអះអាងជាថ្មីអំពីការគាំទ្ររបស់ពួកគេចំពោះសិទ្ធិមនុស្សសកល នៅគ្រប់ជ្រុងនៃពិភពលោក។

យើងខ្ញុំគាំទ្រភាពកាន់តែប្រសើរឡើងនៃចំណងរវាងអាស៊ាន និងសហភាពអឺរ៉ុប និងទទួលស្គាល់នូវសារៈសំខាន់នៃការពង្រឹងទំនាក់ទំនងនៅក្នុងកម្រិតទ្វេភាគី និងអន្តរតំបន់។ ប៉ុន្តែទំនាក់ទំនងបែបនេះចាំបាច់ត្រូវផ្អែកលើភាពរីកចំរើនផ្នែកសង្គម និងនយោបាយ រួមបញ្ចូលទាំងការគោរពសិទ្ធិមនុស្ស និងអភិបាលកិច្ចបែបប្រជាធិបតេយ្យ ហើយបញ្ហាទាំងនេះគួរត្រូវបានដោះស្រាយនៅកម្រិតខ្ពស់បំផុតនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល។

មានភាពចាំបាច់ជាបន្ទាន់សម្រាប់វោហារសាស្ត្រខ្ពស់ ដែលត្រូវគាំទ្រដោយសកម្មភាពពិតប្រាកដ។ មេដឹកនាំអាស៊ានមានទំនួលខុសត្រូវក្នុងការធ្វើសកម្មភាពលើការប្តេជ្ញាចិត្ត ដើម្បីលើកកម្ពស់គោលការណ៍សិទ្ធិមនុស្សសកល ហើយមេដឹកនាំអឺរ៉ុប ដែលជាដៃគូអន្តរជាតិដែលមានការប្តេជ្ញាចិត្តចំពោះសន្តិភាព និងវិបុលសុខប្រកបដោយនិរន្តរភាព នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានទំនួលខុសត្រូវក្នុងការជម្រុញឲ្យមានសកម្មភាពបែបទាំងនេះ។

ក្នុងនាមជាតំណាងជាប់ឆ្នោត វាគឺជាតួនាទីរបស់យើងដើម្បីធានាថា សម្លេងប្រជាពលរដ្ឋរបស់យើងត្រូវបានយកចិត្តទុកដាក់ដោយមេដឹកនាំនៃប្រទេសជាតិរបស់យើង។ នៅក្នុងតួនាទីនេះ យើងខ្ញុំសូមជម្រុញឲ្យឯកឧត្តមរដ្ឋមន្ត្រី គោរពនូវការសន្យាពីមុនៗរបស់ខ្លួន និងមានចំណាត់ការបន្ទាន់ ដើម្បីធានាឲ្យ

មានការដោះលែងអ្នកដែលត្រូវបានឃុំខ្លួន ដោយសារការសម្តែងចេញនូវជំនឿនយោបាយ ឬសាសនារបស់ពួកគេ ហើយចាត់វិធានការដោយសន្តិវិធី ក្នុងការគាំទ្រនូវជំនឿទាំងនោះ។

ការដោះលែងអ្នកទោសមនសិការទាំងអស់  នឹងផ្ញើសារដ៏មានឥទ្ធិពលមួយអំពីការប្តេជ្ញាចិត្តរួមគ្នានៃបណ្តារដ្ឋាភិបាល នៅអឺរ៉ុប និងអាស៊ីអាគ្នេយ៍ ដើម្បីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងដើម្បីធានាថា  កិច្ចសហប្រតិបត្តិការរបស់ពួកយើងទទួលបាននូវអត្ថប្រយោជន៍ប្រកបដោយនិរន្តរភាព  និងទូលំទូលាយ សម្រាប់ប្រជាពលរដ្ឋរបស់យើង។

យើងខ្ញុំសង្ឃឹមថា ឯកឧត្តមរដ្ឋមន្ត្រី នឹងចាត់វិធានការសមរម្យ។

ដោយក្តីស្មោះត្រង់អំពីយើងខ្ញុំ

| | |
|---|---|
| Afzal Khan, MEP | United Kingdom |
| Alice Lau Kiong Yieng, MP | Malaysia |
| Ana Gomes, MEP | Portugal |
| Ariel Casilao (Congressman) | Philippines |
| Aye Mya Mya Myo, MP | Myanmar |
| Azman Ismail, MP | Malaysia |
| Barbara Lochbihler, MEP | Germany |
| Bart Staes, MEP | Belgium |
| Beatriz Becerra Basterrechea, MEP | Spain |
| Boris ZALA, MEP | Slovakia |
| Charles Chong, MP | Singapore |
| Charles Santiago, MP | Malaysia |
| Charles Tannock,MEP | United Kingdom |
| Dang Chamreun, MP | Cambodia |
| David Martin, MEP | United Kingdom |
| Demetris Papadakis, MEP | Cyprus |
| Dr. Laima Liucija Andrikiene, MEP | Lithuania |
| Elena Valenciano, MEP | Spain |
| Elly Schlein, MEP | Italy |
| Francisco Assis, MEP | Portugal |
| Hee Loy Sian MP | Malaysia |
| Heidi Hautala, MEP | Finland |
| Helga Trüpel, MEP | Germany |
| Heng Danaro MP | Cambodia |
| Idris Bin Jusi MP | Malaysia |
| Ignazio Corrao, MEP | Italy |
| Ioan Mirceapaşcu, MEP | Romania |
| Ivo Vajgl, MEP | Slovenia |
| Javier Nart, MEP | Spain |
| Jean Lambert, MEP | United Kingdom |
| Jeff Ooi Chuan Aun, MP | Malaysia |
| Josef Weidenholzer, MEP | Austria |
| Jude Kirton-Darling, MEP | United Kingdom |
| Karlos Isagani Zarate (Congressman) | Philippines |
| Karoline Graswander-Hainz | Austria |

| | |
|---|---|
| Kasit Piromya* | Thailand |
| Kasthuriraani Patto MP | Malaysia |
| Kati PIRI, MEP | Netherlands |
| Keo Phirum MP | Cambodia |
| Khalid Bin Samad MP | Malaysia |
| Khalid Samad MP | Malaysia |
| Khy Vandeth MP | Cambodia |
| Kong Saphea MP | Cambodia |
| Kraisak Choonhavan* | Thailand |
| Lath Littay MP | Cambodia |
| Liew Chin Tong MP | Malaysia |
| Lim Bunsidareth MP | Cambodia |
| Lim Guan Eng MP | Malaysia |
| Lim Kimya MP | Cambodia |
| Long Ry MP | Cambodia |
| Mahdev Mohan MP | Singapore |
| Manivannan Gowin MP | Malaysia |
| Maria Heubuch, MEP | Germany |
| Mark Demesmaeker, MEP | Belgium |
| Mark Tarabella, MEP | Belgium |
| Martin Häusling, MEP | Germany |
| Men Sothavarin MP | Cambodia |
| Michèle RIVASI, MEP | France |
| Mohd Rafizi Ramli MP | Malaysia |
| Mu Sochua MP | Cambodia |
| Ng Wei Aik MP | Malaysia |
| Nga Kor Ming MP | Malaysia |
| Ngeh Koo Ham MP | Malaysia |
| Nurul Izzah Anwar MP | Malaysia |
| Ong Kian Ming MP | Malaysia |
| Oscar Ling Chai Yew MP | Malaysia |
| Ou Chanrath MP | Cambodia |
| Petras Austrevicius, MEP | Lithuania |
| Pier Antonio Panzeri, MEP | Italy |
| Pot Peou MP | Cambodia |
| Real Kamerin MP | Cambodia |
| Richard HOWITT, MEP | United Kingdom |
| Risa Hontiveros (Senator) | Philippines |
| Sabine Loesing, MEP | Germany |
| Sim Chee Keong MP | Malaysia |
| Sim Tong Him MP | Malaysia |
| Sim Tze Tzin MP | Malaysia |
| Sivarasa Rasiah MP | Malaysia |
| Sok Umsea MP | Cambodia |
| Son Chhay MP | Cambodia |
| Su Keong Siong MP | Malaysia |
| Teddy Baguilat Jr. (Congressman) | Philippines |
| Teo Kok Seong MP | Malaysia |
| Tomáš Zdechovsky , MEP | Czech Republic |
| Tomasito Villarin (Congressman) | Philippines |
| Uch Serey Yuth MP | Cambodia |
| Vann Narith MP | Cambodia |
| Vincent Peillon, MEP | France |

| | |
|---|---|
| William Leong Jee Keen MP | Malaysia |
| Wong Chen, MP | Malaysia |
| Yont Tharo, MP | Cambodia |
| Zairil Khir Johari, MP | Malaysia |
| Zuraida Binti Kamaruddin, MP | Malaysia |

***តំណាងរាស្ត្រមកពីប្រទេសថៃ គឺជាអតីតតំណាងរាស្ត្រជាប់ឆ្នោត ដោយសារការព្យួរនៃលទ្ធិប្រជាធិបតេយ្យ បន្ទាប់ពីមានរដ្ឋប្រហារយោធា កាលពីខែឧសភា ឆ្នាំ២០១៤**